ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

# CIAS 41

## កសិកម្ម

## Agriculture

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™

# **អារម្ភកថា**

ដោយសារនយោបាយ "**ឈ្នះ-ឈ្នះ**" របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបាននូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងនូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់នូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១, ទី២ និង ទី៣**", "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**", "**យុទ្ធសាស្ត្រត្រីកោណ**", "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០**" និង "**យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**" ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

**ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ** ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និងក្រុមប្រឹក្សាជាតិគណនេយ្យ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជាក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិងសវនកម្មឯកជន ដើម្បីបង្កើតនូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញកំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័នបញ្ញត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី "**ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា** " ត្រូវបានបកប្រែទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានាបាននូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនករផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួមចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៃ "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**" របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**”។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្តើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឱ្យប្រើនូវច្បាប់ស្តីពី “គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ” នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ *ស្តង់ដារគណនេយ្យកម្ពុជា* ដែលរួមមាន“ *ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា* ” និង *“ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម”* ត្រូវបានដាក់ឱ្យប្រើដោយប្រកាស*លេខ ០៦៨ ស.ហ.វ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ពន្ធ័ ឱ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋលេខាធិការ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**វិ តាយី**

## គោលបំណង

គោលបំណងនៃស្តង់ដានេះ គឺចង់រៀបរាប់ពីការធ្វើគណនេយ្យកម្ម និងការលាតត្រដាងព័ត៌មានគណនេយ្យ ដែលទាក់ទងនឹងសកម្មភាពកសិកម្ម។

## វិសាលភាព

**១ ស្តង់ដានេះត្រូវបានអនុវត្តដើម្បីធ្វើគណនេយ្យកម្មទៅលើចំណុចខាងក្រោម ដែលពួកគេមានការពាក់ព័ន្ធសកម្មភាពកសិកម្ម ÷**

**ក ទ្រព្យសកម្មជីវសាស្ត្រ**

**ខ ផលិតផលកសិកម្មនៅពេលប្រមូលផល និង**

**គ ជំនួយរដ្ឋាភិបាល ដែលនិយាយនៅក្នុងកថាខណ្ឌ ៣៤-៣៥។**

២ ស្តង់ដានេះមិនអនុវត្តចំពោះ ÷

ក ដីធ្លី ដែលពាក់ព័ន្ធនឹងសកម្មភាពកសិកម្ម(សូមមើលស.គ.អ.ក ១៦ *ទ្រព្យ រោងចក្រ និង បរិក្ខារ* និង ស.គ.អ.ក ៤០ *ទ្រព្យវិនិយោគ*) និង

ខ ទ្រព្យសកម្មអរូបិយទាក់ទងទៅនឹងសកម្មភាពកសិកម្ម (សូមមើល ស.គ.អ.ក ៣៨ *ទ្រព្យសកម្មអរូបិយ*)

៣ ស្តង់ដានេះអនុវត្តចំពោះផលិតផលកសិកម្ម ដែលជាផលិតផលប្រមូលបានពីទ្រព្យសកម្មជីវសាស្ត្ររបស់សហគ្រាសមួយ តែនៅពេលប្រមូលផលប៉ុណ្ណោះ។ ក្រោយមក ស្តង់ដា ស.គ.អ.ក ២ សន្និធិ ឬស្តង់ដាណាមួយផ្សេងទៀត ត្រូវបានអនុវត្ត។

ហេតុដូច្នេះហើយបានជាស្តង់ដានេះ មិនពាក់ព័ន្ធជាមួយដំណើរការកែច្នៃផលិតផល កសិកម្មក្រោយពេលប្រមូលផលឡើយ÷ ឧទាហរណ៍ ការកែច្នៃផ្លែទំពាំងបាយជូរឱ្យទៅជាស្រាដោយអ្នកបិតស្រា ដែលជាអ្នកបានដាំផ្លែទំពាំងបាយជូរនោះ ។ ខណៈដែលការកែច្នៃបែបនេះអាចជាការបន្តនូវសកម្មភាពកសិកម្ម ដ៏សមហេតុផល និងតាមលក្ខណៈធម្មជាតិមួយនោះ ហើយព្រឹត្តិការណ៍ដែលកើតឡើង អាចមានលក្ខណៈប្រហាក់ប្រហែលគ្នាខ្លះទៅ នឹងការបម្លែងជីវសាស្ត្រក៏ដោយដំណើរការកែច្នៃនេះ មិនត្រូវរួមបញ្ចូលនៅក្នុងនិយមន័យនៃសកម្មភាពកសិកម្មក្នុងស្តង់ដារនេះដែរ ។

៤ តារាងខាងក្រោមនេះផ្តល់នូវឧទាហរណ៍ទាំងឡាយអំពីទ្រព្យសកម្មជីវ-សាស្ត្រ ផលិតផលកសិកម្ម និងផលិតផលកសិកម្មដែលបានមកពីការកែច្នៃបន្ទាប់ពីការប្រមូលផល ÷

| ទ្រព្យសកម្មជីវសាស្ត្រ | ផលិតផលកសិកម្ម | ផលិតផលកសិកម្មដែលបានមកការកែច្នៃបន្ទាប់ពីការប្រមូលផល |
|---|---|---|
| ចៀម | រោមចៀម | អំបោះ ព្រំ |
| ដើមឈើក្នុងចំការព្រៃ | ឈើមូល | ឈើអាររួច |
| ដំណាំ | សំឡី | អំបោះ សម្លៀកបំពាក់ |
| | អំពៅ | ស្ករ |
| គោចិញ្ចឹមយកទឹកដោះ | ទឹកដោះគោ | ឈីស (Cheese) |
| ជ្រូក | ជ្រូកសំលាប់រួច | សាច់ក្រក សាច់ងៀត |
| ដំណាំយកស្លឹក | ស្លឹក | តែ ថ្នាំជក់ចំហុយ |
| ទំពាំងបាយជូ | ផ្លែទំពាំងបាយជូ | ស្រា |

| | | |
|---|---|---|
| ដើមឈើហូបផ្លែ | ផ្លែឈើបេះពីដើម | ផ្លែឈើកែច្នៃរួច |

## និយមន័យ

### និយមន័យទាក់ទងនឹងកសិកម្ម

៥ ពាក្យស័ព្ទខាងក្រោម ត្រូវបានប្រើប្រាស់នៅក្នុងស្តង់ដានេះ ដោយមានអត្ថន័យបញ្ជាក់ដូចខាងក្រោមៈ

*សកម្មភាពកសិកម្ម*គឺជាការគ្រប់គ្រងដោយសហគ្រាសមួយលើការបម្លែងតាមបែបជីវសាស្ត្រនិងការប្រមូលផលនៃទ្រព្យសកម្មជីវសាស្ត្រសម្រាប់លក់ ឬបំលែងទៅជាផលិតផលកសិកម្ម ឬទ្រព្យសកម្មជីវសាស្ត្របន្ថែមទៀត ។

*ផលិតផលកសិកម្ម*

គឺជាផលិតផលដែលបានប្រមូលផលរួចនៃទ្រព្យសកម្មជីវសាស្ត្ររបស់សហគ្រាសមួយ ។

*ទ្រព្យជីវសាស្ត្រ*គឺជាសត្វរស់មួយក្បាល ឬ ដំណាំរស់មួយដើម

*ការបំលែងតាមជីវសាស្ត្រ*រួមមានដំណើរការនៃការរីកធំធាត់ ការពុកផុយ ការផលិត និងជាតិកម្ម ដែលធ្វើឱ្យមានការផ្លាស់ប្តូរទាំងបរិមាណ និងគុណភាព នៅក្នុងទ្រព្យសកម្មជីវសាស្ត្រមួយ ។

*ថ្លៃដើមដើម្បីលក់*គឺជាចំណាយបន្ថែមដែលចូលរួមដោយផ្ទាល់ចំពោះការលក់ទ្រព្យសកម្មមួយ ដោយមិនរាប់បញ្ចូលថ្លៃដើមហិរញ្ញវត្ថុ និង ពន្ធលើប្រាក់ចំណូល។

*ក្រុមទ្រព្យសកម្មជីវសាស្ត្រ* គឺជាបណ្តុំនៃសត្វមានជីវិតឬដំណាំដែលប្រហាក់ប្រហែលគ្នា ។

*ការប្រមូលផល* **គឺជាការផ្តាច់យកផលិតផល ពីទ្រព្យសកម្មជីវសាស្ត្រមួយ ឬជាការបញ្ចប់នូវដំណើរជីវិត នៃទ្រព្យសកម្មជីវសាស្ត្រមួយ ។**

៦ សកម្មភាពកសិកម្មគ្របដណ្តប់ទៅលើសកម្មភាពច្រើនប្រភេទ ឧទាហរណ៍ ការចិញ្ចឹមបសុសត្វ ព្រៃឈើ ការដាំដំណាំតាមឆ្នាំ ឬ រយៈពេលយូរអង្វែង កាដាំដំណាំយកផ្លែបុប្ផវប្បកម្ម(បុប្ផា)និងវារីវប្បកម្ម(រួមទាំងការចិញ្ចឹមត្រី)។ ទិដ្ឋភាពរួមមួយចំនួនមាននៅក្នុងភាពផ្សេងៗគ្នានេះ ÷

(ក) *សមត្ថភាពក្នុងការផ្លាស់ប្តូរ*។ សត្វមានជីវិត និងដំណាំ គឺជាសមត្ថភាពនៃការបម្លែងជីវសាស្ត្រ

(ខ) *ការគ្រប់គ្រងការផ្លាស់ប្តូរ*។ គ្រប់គ្រងសម្រួលដល់ការបម្លែងជីវ-សាស្ត្រ ដោយធ្វើឱ្យកាន់តែប្រសើរឡើង ឬយ៉ាងហោចណាស់ធ្វើឱ្យមានស្ថេរភាព ដោយស្ថានភាពចាំបាច់សម្រាប់ការដាក់ឱ្យដំណើរការ (ឧទាហរណ៍ កម្រិតជីវជាតិចំណីអាហារ សំណើមសីតុណ្ហភាព ជីជាតិ និងពន្លឺ)។ការគ្រប់គ្រងបែបនេះបានញែកសកម្មភាពកសិកម្មដាច់ចេញពីសកម្មភាពផ្សេងទៀត។ឧទាហរណ៍ ការប្រមូលផលពីប្រភពទាំងឡាយណាដែលមិនមានការគ្រប់គ្រង (ដូចជា ការនេសាទក្នុងមហាសមុទ្រ និងការកាប់បំផ្លាញព្រៃឈើ) គឺមិនមែនជាសកម្មភាពកសិកម្មទេ និង

(គ) *ការវាស់វែងនូវការផ្លាស់ប្តូរ*។ ការផ្លាស់ប្តូរគុណភាព (ឧទាហរណ៍ ការលូតលាស់នៃពូជ ដង់ស៊ីតេ ភាពទុំ ស្រទាប់ខ្លាញ់ បរិមាណប្រូតេអ៊ីន កម្លាំងសរសៃ ) ឬបរិមាណ (ឧទាហរណ៍ កូនទម្ងន់ម៉ែត្រគូប ប្រវែងសរសៃ ឬទំហំសរសៃ និង ចំនួនគ្រាប់)

ដែលកើតមានឡើង ដោយការបម្លែង ជីវសាស្ត្រត្រូវបានវាស់វែង និង តាមដានក្នុងលក្ខណៈជាមុខងារគ្រប់គ្រងដដែលៗមួយ។

៧ ការបម្លែងតាមជីវសាស្ត្រ បណ្តាលឱ្យមានទិន្នផលច្រើនប្រភេទ ដូចខាងក្រោម ÷

(ក) ទ្រព្យសកម្មផ្លាស់ប្តូរតាមរយៈ (១) ការរីកលូតលាស់ (កំណើននូវបរិមាណ ឬ ភាពប្រសើរឡើង នៃគុណភាពនៃសត្វ ឬ ដំណាំ) (២) ការអន់ថយ (ការថយចុះបរិមាណ ឬការថមថយ គុណភាពនៃសត្វ ឬដំណាំ) ឬ(៣) ជាតិកម្ម (ការបង្កាត់ពូជនូវជីវិតសត្វ ឬដំណាំថ្មី) ឬ

(ខ) ផលិតកម្ម នៃផលិតផលកសិកម្ម ដូចជា ជ័រឈើ ស្លឹកតែ រោម និង ទឹកដោះ

## និយមន័យទូទៅ

**៨ ពាក្យស័ព្ទខាងក្រោម ត្រូវបានប្រើនៅក្នុងស្តង់ដានេះ ដោយមានន័យបញ្ជាក់ខាងក្រោម ÷**

***ទីផ្សារសកម្ម*** **គឺជាផ្សារដែលបំពេញនូវលក្ខខណ្ឌដូចខាងក្រោម ÷**

**(ក) ទំនិញដែលលក់ដូរនៅក្នុងផ្សារ គឺមានភាពដូចគ្នា ឬប្រហាក់ប្រហែលគ្នា**

**(ខ) ឆន្ទៈរបស់អ្នកទិញ និង អ្នកលក់ អាចមានគ្រប់ពេលជាធម្មតា និង**

**(គ) តម្លៃអាចទទួលយក សម្រាប់សាធារណជន**

***តម្លៃយោង*****គឺជាតម្លៃដែលគេទទួលស្គាល់ចំពោះទ្រព្យសកម្មនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។**

*តម្លៃសមស្រប* **គឺជាទឹកប្រាក់ ដែលទ្រព្យសកម្មមួយអាចត្រូវដោះដូរ ឬ បំណុលដែលត្រូវទូទាត់រវាងភាគី ដែលមានឆន្ទៈ និងយល់ដឹង នៅក្នុងប្រតិបត្តិការបើកចំហ។**

*ជំនួយរដ្ឋាភិបាល* **ដូចដែលបានកំណត់និយមន័យនៅក្នុង ស.គ.អ.ក ២០** ***គណនេយ្យសម្រាប់ជំនួយរដ្ឋាភិបាល និងការលាតត្រដាងពីជំនួយរដ្ឋាភិបាល*។**

៩ តម្លៃសមស្របនៃទ្រព្យសកម្មមួយ គឺអាស្រ័យលើទីតាំង និងស្ថានភាពបច្ចុប្បន្នរបស់វា ។ ឧទាហរណ៍ ជាលទ្ធផលតម្លៃសមស្របរបស់គោមួយនៅឯចំការ គឺជាតម្លៃសម្រាប់គោនោះនៅទីផ្សារពាក់ព័ន្ធ ដកចេញនូវចំណាយលើការដឹកជញ្ជូន និង ការចំណាយផ្សេងៗ

## ការទទួលស្គាល់ និង ការវាស់វែង

**១០ សហគ្រាសមួយ អាចទទួលស្គាល់ទ្រព្យសកម្មជីវសាស្ត្រមួយ ឬផលិតផលកសិកម្មមួយ នៅពេលដែល និងតែនៅពេលដែល:**

**(ក) សហគ្រាសត្រួតត្រាលើទ្រព្យសកម្មនោះ ដែលជាលទ្ធផលមួយបានមកពីព្រឹត្តិការណ៍អតីតកាល**

**(ខ) វាទំនងជាថា ផលប្រយោជន៍សេដ្ឋកិច្ច ដែលមានការជាប់ពាក់ព័ន្ធជាមួយនឹងទ្រព្យសកម្មនោះ នឹង ហូរចូលមកសហគ្រាសនោះ។**

**(គ) តម្លៃសមស្របឬថ្លៃដើមនៃទ្រព្យសកម្មនោះ អាចវាស់វែងដោយជឿជាក់បាន ។**

១១ នៅក្នុងសកម្មភាពកសិកម្ម ការត្រួតត្រាអាចស្តែងឡើង ឧទាហរណ៍តាមរយៈកម្មសិទ្ធិស្របច្បាប់លើគោ និងស្នាមបោះត្រា ឬសញ្ញាសម្គាល់លើ

គោនោះ នៅពេលទិញកើត ឬពេលផ្តាច់ដោះ ។ ផលប្រយោជន៍នាពេលអនាគត ជាធម្មតាអាចវាយតម្លៃបានតាមរយៈ ការវាស់វែងលើការសន្ទតរូបរាងជាសំខាន់។

១២ **ទ្រព្យសកម្មជីវសាស្ត្រ អាចវាស់វែង នៅពេលមានការទទួលស្គាល់ជាដំបូង និង នៅរាល់ថ្ងៃតុល្យការ នីមួយៗ នូវតម្លៃសមស្របរបស់វាដកចេញតម្លៃប៉ាន់ស្មាននៅពេលលក់ លើកលែងតែ ចំពោះករណីដែលបានពណ៌នានៅក្នុងកថាខណ្ឌ ៣០ ដែលតម្លៃសមស្របមិនអាចវាស់វែងគួរឱ្យជឿបាន ។**

១៣ **ផលិតផលកសិកម្ម ដែលបានប្រមូលផលពីទ្រព្យសកម្មជីវសាស្ត្ររបស់សហគ្រាសមួយ អាចត្រូវបានវាស់វែង ដោយតម្លៃសមស្របរបស់វាដកចេញថ្លៃដើមប៉ាន់ស្មាននៅពេលលក់ ត្រង់ចំនុចនៃពេលប្រមូលផល។ ការវាស់វែងរបៀបនេះ ជាថ្លៃដើមនៅថ្ងៃនោះ ពេលដែលអនុវត្តនូវ ស.គ.អ.ក ២** ***សន្និធិ*** **ឬក៏ស្តង់ដាណាមួយផ្សេងទៀត ដែលអាចអនុវត្តបាន។**

១៤ [លុបចោល]

១៥ ការកំណត់តម្លៃសមស្របសម្រាប់ទ្រព្យសកម្មជីវសាស្ត្រ ឬផលិតផលកសិកម្មអាចកំណត់ទៅបានដោយការរៀបចំដាក់ជាក្រុមនូវទ្រព្យសកម្មជីវ-សាស្ត្រ ឬផលិតផលកសិកម្មស្របតាមភិនភាគជាចាំបាច់នានា ឧទាហរណ៍តាមអាយុ ឬគុណភាព។ សហគ្រាសមួយ ជ្រើសរើសនូវភិនភាគទាំងនេះ អាស្រ័យទៅលើភិនភាគនោះ ដែលគេនិយមប្រើវានៅទីផ្សារ ដើម្បីធ្វើជាមូលដ្ឋាននៃការកំណត់តម្លៃ។

១៦ សហគ្រាសនានា តែងចុះកិច្ចសន្យា ដើម្បីលក់ទ្រព្យសកម្មជីវសាស្ត្រ ឬផលិតផលកសិកម្មរបស់ពួកគេនៅថ្ងៃអនាគត ។ តម្លៃកិច្ចសន្យា មិនចាំបាច់ពាក់ព័ន្ធទៅនឹងការកំណត់តម្លៃសមស្របទេ

ព្រោះថាតម្លៃសមស្របឆ្លុះបញ្ចាំងអំពីតម្លៃនៅលើទីផ្សារបច្ចុប្បន្នដែលអ្នកទិញនិងអ្នកលក់មានបំណងចង់ទិញនិងលក់ និងអាចនឹងឈានទៅដល់កិច្ចការជំនួញមួយ ។ ជាលទ្ធផល តម្លៃសមស្របនៃទ្រព្យសកម្មជីវសាស្រ្ត ឬផលិតផលកសិកម្ម មិនត្រូវបានធ្វើនិយ័តភាពទេ ដោយសារតែគេបាននិយាយនៅក្នុងកិច្ចសន្យាហើយ ។ ករណីខ្លះ កិច្ចសន្យាលក់ទ្រព្យសកម្មជីវសាស្រ្ត ឬផលិតផលកសិកម្មជាកិច្ចសន្យាធ្វើឱ្យមានការខាតបង់នាពេលអនាគតដូចដែលបានកំណត់នៅក្នុងស.គ.អ.ក៣៧សំវិធានធនបំណុលយថាភាពនិងទ្រព្យសកម្មយថាភាព ។ ស.គ.អ.ក៣៧ *សំវិធានធនបំណុលយថាហេតុនិងទ្រព្យសកម្មយថាហេតុ។* ស.គ.អ.ក ៣៧ អនុវត្តចំពោះកិច្ចសន្យាធ្វើឱ្យមានការខាតបង់នាពេលអនាគត។

១៧ ប្រសិនបើជាមានទីផ្សារកសិកម្មមួយ សម្រាប់ទ្រព្យសកម្មជីវសាស្រ្ត និងផលិតផលកសិកម្ម តម្លៃដកស្រង់នៅ ក្នុងទីផ្សារនោះ គឺជាមូលដ្ឋានសមស្របសម្រាប់កំណត់តម្លៃសមស្របនៃទ្រព្យសកម្មនោះ ។ ប្រសិនបើសហគ្រាស មួយមានលទ្ធភាពចូលទៅកាន់ទីផ្សារសកម្មផ្សេងទៀត អង្គភាពនោះ ត្រូវប្រើតម្លៃមួយដែលពាក់ព័ន្ធបំផុត។ ឧទាហរណ៍ បើសហគ្រាសណាមួយបានទៅកាន់ទីផ្សារពីរផ្សេងគ្នា សហគ្រាសនោះ ត្រូវប្រើតម្លៃដែលមាននៅក្នុងទីផ្សារដែលគេរំពឹងថានឹងប្រើប្រាស់វា ។

១៨ ប្រសិនបើ មិនមានទីផ្សារសកម្មមួយទេ សហគ្រាសត្រូវប្រើវិធីមួយ ឬ ច្រើនខាងក្រោម (នៅពេលដែល មាន) ដើម្បីកំណត់នូវតម្លៃសមស្រប ÷

(ក) តម្លៃប្រតិបត្តិការទីផ្សារបច្ចុប្បន្នភ្លាមៗថ្មីបំផុត ដោយដឹងថាមិនមានការប្រែប្រួលចាំបាច់នៃស្ថានភាពសេដ្ឋកិច្ច នៅចន្លោះថ្ងៃប្រតិបត្តិការនោះ និងចុងការិយបរិច្ឆេទរាយការណ៍ ។

(ខ) តម្លៃទីផ្សារសម្រាប់ទ្រព្យសកម្មប្រហាក់ប្រហែលគ្នា ដោយមានការធ្វើនិយ័តភាព ដើម្បីបង្ហាញពីភាពខុសគ្នានានា

(គ) បទដ្ឋានវិស័យ ដូចជា តម្លៃឈើហូបផ្លែ ដែលគិតក្នុងមួយចំការដែលសំដែងជា មួយស្តុក មួយតៅ ឬមួយហិចតា និងតម្លៃគោ ក្របីដែលគិតក្នុងមួយគីឡូក្រាមសាច់។

១៩ ក្នុងករណីខ្លះ ប្រភពព័ត៌មានដែលបានរៀបរាប់ក្នុងកថាខណ្ឌ ១៨ អាចផ្តល់នូវការសន្និដ្ឋានខុសគ្នា ចំពោះតម្លៃសមស្របនៃទ្រព្យសកម្មជីវសាស្ត្រ ឬផលិតផលកសិកម្ម ។ សហគ្រាសមួយត្រូវពិចារណាពីហេតុផលនានា សម្រាប់ភាពខុសគ្នាទាំងនោះ ដើម្បីឈានដល់ការប៉ាន់ស្មានមួយដែលអាចទុកចិត្តបានកម្រិតខ្ពស់បំផុតនៃតម្លៃសមស្រប និងការប៉ាន់ស្មានតម្លៃកាន់តែមានភាពសមហេតុផល។

២០ ក្នុងស្ថានភាពខ្លះ តម្លៃដែលកំណត់ដោយទីផ្សារ ឬតម្លៃទាំងឡាយ អាចរកមិនបានសម្រាប់ទ្រព្យសកម្ម ជីវសាស្ត្រមួយក្នុងលក្ខខណ្ឌបច្ចុប្បន្ន ។ ក្នុងស្ថានភាពទាំងនេះ សហគ្រាសអាចប្រើនូវតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់សុទ្ធ ដែលរំពឹងទុកពីទ្រព្យសកម្មដែលប្រើវិធីសាស្ត្រអប្បហារ ដោយប្រើប្រាស់អត្រាមុនបង់ពន្ធកំណត់តម្លៃសមស្របបច្ចុប្បន្ន ក្នុងការកំណត់តម្លៃសមស្រប។

២១ កម្មវត្ថុនៃការគណនានៃតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់សុទ្ធរំពឹងទុកមួយគឺដើម្បីកំណត់នូវតម្លៃសមស្រប នៃទ្រព្យសកម្មជីវសាស្ត្រមួយ នៅទីតាំងនិងលក្ខខណ្ឌបច្ចុប្បន្នរបស់វា។សហគ្រាសមួយត្រូវពិចារណាក្នុងការកំណត់នូវអត្រាអប្បហារសម្រាប់ប្រើប្រាស់ និងក្នុងការប៉ាន់ស្មាននូវលំហូរសាច់ប្រាក់សុទ្ធដែលរំពឹងទុក។

នៅក្នុងការកំណត់តម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ពិតដែលបានរំពឹងទុក អង្គភាពមួយបញ្ចូលលំហូរសាច់ប្រាក់ដែលអ្នកចូលរួមទីផ្សារនឹងរំពឹងថា ទ្រព្យសកម្មនឹងអាចរកបាននៅក្នុងទីផ្សារ ទាក់ទិនបំផុតរបស់វា។

២២ សហគ្រាសមួយ មិនត្រូវបញ្ចូលនូវលំហូរសាច់ប្រាក់ណាមួយ សម្រាប់ធ្វើហិរញ្ញប្បទានទ្រព្យសកម្មនោះ ការដាក់ពន្ធ ឬការបង្កើតឡើងវិញនូវទ្រព្យសកម្មជីវសាស្រ្តបន្ទាប់ពីការប្រមូលផលឡើយ (ឧទាហរណ៍ ថ្លៃដើមនៃការដាំដើមឈើឡើងវិញនៅក្នុងចំការមួយបន្ទាប់ពីការប្រមូលផល)។

២៣ ក្នុងការព្រមទទួលយកតម្លៃត្រឹមត្រូវអ្នកទិញនិងអ្នកលក់ដែលមានការស្ម័គ្រចិត្ត និងមានចំណេះដឹង ត្រូវពិចារណានូវលទ្ធភាពនៃការប្រែប្រួលលំហូរសាច់ប្រាក់ ។ តម្លៃសមស្របនោះ វាឆ្លុះបញ្ចាំងឱ្យឃើញលទ្ធភាពនៃការប្រែប្រួលនោះ។ អាស្រ័យដូចនេះ សហគ្រាសមួយត្រូវរំពឹងទុកជាមុនអំពីលទ្ធភាពនៃបម្រែបម្រួលនោះ ទាំងនៅក្នុងលំហូរសាច់ប្រាក់រំពឹងទុក ឬអត្រាអប្បហារឬបន្សំនៃករណីទាំងពីរនេះ។ក្នុងការកំណត់នូវអត្រាអប្បហារមួយ សហគ្រាសត្រូវប្រើនូវវិធីសាស្រ្តសន្មតនានា ឱ្យមានភាពស៊ីសង្វាក់គ្នាទៅនឹងវិធីសាស្រ្ត ដែលបានប្រើក្នុងការប៉ាន់ស្មាននូវលំហូរសាច់ប្រាក់រំពឹងទុក ដើម្បីបញ្ចៀសនូវផលប៉ះពាល់នៃការសន្មតមួយចំនួនដែលត្រូវបានរាប់ពីរដង ឬត្រូវបានបំភ្លេច។

២៤ ជួនកាល ថ្លៃដើមអាចប៉ាន់ស្មានប្រហាក់ប្រហែលគ្នាទៅនឹងតម្លៃសមស្របជាពិសេសនៅពេល ÷

(ក) មានការបម្លែងជីវសាស្រ្តតិចតួច ចាប់តាំងពីកើតមានថ្លៃដើមដំបូង (ឧទាហរណ៍ សម្រាប់គ្រាប់ដើម ឈើយកផ្លែដែលបានដាំភ្លាមៗមុនថ្ងៃតុល្យការ) ឬ

(ខ) ផលប៉ះពាល់នៃការបម្លែងជីវសាស្ត្រលើតម្លៃ គឺមិនរំពឹងថាមានភាពធំដុំ (ឧទាហរណ៍ សម្រាប់កំណើនដំបូងក្នុងវដ្តផលិតកម្មរយៈពេល៣០ឆ្នាំ នៃចំការស្រល់ជាដើម)។

២៥ ទ្រព្យសកម្មជីវសាស្ត្រជាញឹកញាប់ផ្សាភ្ជាប់ជារូបធាតុទៅនឹងដី (ឧទាហរណ៍ ដើមឈើនៅក្នុងចំការព្រៃឈើ )។ ប្រហែលជាមិនមានទីផ្សារដាច់ដោយឡែកចំពោះទ្រព្យសកម្មជីវសាស្ត្រ ដែលភ្ជាប់ខ្លួនទៅនឹងដីបានទេ ប៉ុន្តែទីផ្សារសកម្មមួយ អាចមានសម្រាប់ទ្រព្យសកម្មរួមគ្នាជាកញ្ចប់មួយ គឺថាទ្រព្យសកម្ម ជីវសាស្ត្រដីទទេ និងការកែលំអដី ។ សហគ្រាសមួយអាចប្រើព័ត៌មាន ចំពោះទ្រព្យសកម្មរួមគ្នានេះ ដើម្បីកំណត់តម្លៃសមស្របសម្រាប់ទ្រព្យសកម្មជីវសាស្ត្រ ។ ឧទាហរណ៍ តម្លៃសមស្របនៃដីទទេ និងការកែលម្អដី អាចត្រូវកាត់បន្ថយចេញពីតម្លៃសមស្របនៃទ្រព្យសកម្មរួមគ្នា ដើម្បីទទួលឱ្យបាននូវតម្លៃសមស្របនៃទ្រព្យ សកម្មជីវសាស្ត្រ ។

**ចំណេញ និង ខាត**

**២៦ ចំណេញ ឬខាត ដែលកើតឡើងនៅពេលទទួលស្គាល់ដំបូង នៃទ្រព្យសកម្មជីវសាស្ត្រតាមតំលៃទីផ្សារ ដោយដកចេញ ថ្លៃដើមប៉ាន់ស្មាននៅពេលលក់ និងកើតចេញពីការប្រែប្រួលនៃតំលៃទីផ្សារ ដោយដកចេញថ្លៃដើមប៉ាន់ស្មាននៅពេលលក់នៃទ្រព្យសកម្មជីវសាស្ត្រ ត្រូវចាត់បញ្ចូលទៅក្នុងចំណេញ ឬខាតពិត សម្រាប់ការិយបរិច្ឆេទ ដែលវាកើតឡើង។**

២៧ ការខាតណាមួយ អាចកើតឡើងនៅគ្រាទទួលស្គាល់ដំបូង នៃទ្រព្យសកម្មជីវសាស្ត្រ ពីព្រោះថ្លៃដើមប៉ាន់ស្មានត្រង់ចំណុចលក់ ត្រូវបានដកចេញក្នុងការកំណត់តំលៃទីផ្សារ ដកចេញថ្លៃដើមប៉ាន់ស្មានត្រង់ចំណុចលក់ នៃទ្រព្យ-

សកម្មជីវសាស្ត្រ ។ ចំណេញអាចកើតឡើងនៅគ្រាទទួលស្គាល់ដំបូងនៃទ្រព្យសកម្មជីវសាស្ត្រ ដូចជាពេលដែលកូនគោបានចាប់កំណើត ។

២៨ **ចំណេញ ឬខាត ដែលកើតចេញពីការទទួលស្គាល់គ្រាដំបូង នៃផលិតផលកសិកម្ម ត្រង់តំលៃទីផ្សារដក ចេញថ្លៃដើមប៉ាន់ស្មានត្រង់ចំណុចលក់ ត្រូវចាត់បញ្ចូលទៅក្នុង ចំណេញ ឬខាតពិតសម្រាប់ការិយបរិច្ឆេទ ដែលវាកើតឡើង ។**

២៩ ចំណេញ ឬខាតដែលកើតចេញពីការទទួលស្គាល់គ្រាដំបូង នៃផលិតផលកសិកម្ម គឺជាលទ្ធផលនៃការប្រមូលផល ។

អលទ្ធភាពវាស់វែងតម្លៃសមស្របដោយជឿជាក់

៣០ **មានការសន្មតជាមុនថា**

**តំលៃសមស្របអាចត្រូវគេវាស់វែងដោយជឿជាក់បានសម្រាប់ទ្រព្យសកម្មជីវសាស្ត្រ មួយ។ ទោះយ៉ាងណាការសន្មតនេះ អាចត្រូវបានច្រានចោលវិញនៅ គ្រាទទួលស្គាល់ដំបូងចំពោះទ្រព្យសកម្មជីវសាស្ត្រមួយ ដែលថ្លៃ ឬតំលៃកំណត់ដោយទីផ្សារមិនអាចរកបាន ហើយដែលការប៉ាន់ស្មានពីតំលៃសមស្របតាមជម្រើសមួយទៀត ត្រូវគេគិតថាមិនអាចជឿជាក់បានយ៉ាងច្បាស់លាស់ ។ ក្នុងករណីនេះ ទ្រព្យសកម្មជីវសាស្ត្រនោះ គួរវាស់វែងនៅត្រង់ថ្លៃដើមរបស់វា ដកចេញរំលស់បង្គរណាមួយ និងការខាតបង់បង្គរដោយការខូចខាតតំលៃណាមួយ។ ខណៈពេលដែលតំលៃទីផ្សារនៃទ្រព្យសកម្មជីវសាស្ត្រនេះ អាចវាស់វែង ដោយជឿជាក់បានវិញ សហគ្រាសនោះត្រូវវាស់វែងវាជាតំលៃទីផ្សារ ដកចេញថ្លៃដើមប៉ាន់ស្មាន ត្រង់ចំណុចលក់។ ខណៈពេលដែលទ្រព្យសកម្មជីវសាស្ត្រអចល័តមួយ បំពេញបានតាមលក្ខណៈ**

**វិនិច្ឆ័យ ត្រូវបានចំណាត់ថ្នាក់ជាទ្រព្យសម្រាប់លក់ (ឬបញ្ចូលទៅក្នុងក្រុមសម្រាប់លក់បញ្ចេញចោល ដែលចំណាត់ថ្នាក់ជាទ្រព្យសម្រាប់លក់) ដោយយោងទៅតាមស្តង់ដារ ស.រ.ហ.អ.ក ៥** *ទ្រព្យសកម្មរយៈពេលវែងរក្សារទុកសម្រាប់លក់ និងកិច្ចប្រតិបត្តិការមិនបន្ត* **គេបានសន្មតវាថាជាតំលៃសមស្របអាចវាស់វែងបាន ដោយជឿជាក់ ។**

៣១ ការសន្មតក្នុងកថាខណ្ឌ ៣០ អាចត្រូវគេបដិសេធ តែនៅពេលទទួលស្គាល់គ្រាដំបូងប៉ុណ្ណោះ ។ សហគ្រាស មួយដែលពីគ្រាមុនៗ បានវាស់វែងទ្រព្យសកម្មជីវសាស្រ្តតាមតម្លៃសមស្របរបស់វាដកចេញថ្លៃដើមប៉ាន់ស្មានត្រង់ចំណុចលក់ ត្រូវបន្តវាស់វែងទ្រព្យសកម្មជីវសាស្រ្ត តាមតំលៃទីផ្សាររបស់វាដកចេញថ្លៃដើម ប៉ាន់ស្មានត្រង់ចំណុចលក់រហូតដល់ពេលលក់បញ្ចេញចោល។

៣២ ក្នុងរាល់ករណីទាំងអស់ សហគ្រាសមួយ វាស់វែងផលិតផលកសិកម្ម នៅចំនុចនៃការប្រមូលផល តាមតំលៃទីផ្សាររបស់វា ដកចេញថ្លៃដើមប៉ាន់ស្មានត្រង់ចំណុចលក់ ។ ស្តង់ដារនេះ ឆ្លុះបញ្ចាំងទស្សនះឱ្យឃើញថាតំលៃទីផ្សារនៃផលិតផលកសិកម្មនៅចំនុចនៃការប្រមូលផល ជានិច្ចកាលអាចវាស់វែងដោយ ជឿជាក់បាន។

៣៣ ក្នុងការកំណត់ថ្លៃដើម រំលស់បង្គរ និងការខាតបង់ដោយការថយចុះតំលៃបង្គរសហគ្រាសមួយពិចារណា ស.គ.អ.ក ២, ស.គ.អ.ក ១៦ និង ស.គ.អ ៣៦ *ការធ្លាក់ចុះតម្លៃនៃទ្រព្យសកម្ម*។

៣៤ ជំនួយរដ្ឋាភិបាលដែលឥតលក្ខខណ្ឌទាក់ទងទៅនឹង ទ្រព្យសកម្មជីវសាស្រ្ត ដែលវាស់វែងតាមតម្លៃទីផ្សាររបស់វាដកចេញថ្លៃដើមប៉ាន់ស្មានត្រង់ចំណុចលក់គួរទទួលស្គាល់ជាចំណូលនៅពេលដែល (និងមានតែពេលនេះមួយគត់) ប្រាកដថាជំនួយរដ្ឋាភិបាលនឹងត្រូវបានទទួល។

៣៥ ប្រសិនបើជំនួយរដ្ឋាភិបាលមួយ ពាក់ពន្ធ័នឹងទ្រព្យសកម្មជីវសាស្រ្ត ដែលវាស់វែងតាមតំលៃទីផ្សាររបស់វាដកចេញ ថ្លៃដើមប៉ាន់ស្មានត្រង់ចំណុចលក់ បែរជាមានលក្ខខណ្ឌ ដែលរួមមានករណីរដ្ឋាភិបាល តម្រូវឱ្យសហគ្រាសមួយមិនឱ្យចូលរួមនៅក្នុងសកម្មភាពកសិកម្មណាមួយ សហគ្រាសគួរទទួលស្គាល់ជាចំណូល នៅពេលដែល (និងមានតែពេលនេះមួយគត់) លក្ខខណ្ឌភ្ជាប់ជាមួយនឹងជំនួយរដ្ឋាភិបាលត្រូវបានបំពេញ។

៣៦ លក្ខខណ្ឌនៃជំនួយរដ្ឋាភិបាលមានលក្ខណៈប្រែប្រួល ។ ឧទាហរណ៍ ជំនួយរដ្ឋាភិបាល អាចនឹងតំរូវឱ្យសហគ្រាស មួយដាំដុះ នៅទីតាំងជាក់លាក់មួយរយៈពេល៥ឆ្នាំ និងទាមទារឱ្យសហគ្រាសនេះ ប្រគល់ត្រឡប់វិញនូវជំនួយទាំងអស់នេះ ប្រសិនបើសហគ្រាស ដាំដុះបានរយៈពេលតិចជាង៥ឆ្នាំនោះ ។ ក្នុងករណីនេះ ជំនួយរដ្ឋាភិបាលមិនត្រូវបានទទួលស្គាល់ជាចំណូលទេ រហូតទាល់តែរយៈពេល៥ឆ្នាំ បានកន្លងផុតទៅ។ ទោះជាយ៉ាងនេះ ប្រសិនបើជំនួយរដ្ឋាភិបាល អនុញ្ញាតឱ្យរក្សាទុកផ្នែកណាមួយនៃជំនួយដោយផ្អែកលើ ការកន្លងផុតទៅនៃពេលវេលា សហគ្រាសអាចទទួលស្គាល់ជំនួយនេះជាចំណូល ដោយលើមូលដ្ឋានសមាមាត្រពេលវេលា។

៣៧ ប្រសិនបើជំនួយរដ្ឋាភិបាលពាក់ពន្ធ័ទៅនឹង ទ្រព្យសកម្មជីវសាស្ត្រដែលវាស់វែងតាមថ្លៃដើមរបស់វាដកចេញរំលស់បូកបន្ត និងការខាតបង់ដោយសារការថយចុះតំលៃបូកបន្តនោះ (សូមមើល កថាខណ្ឌ ៣០) ស.គ.អ.ក ២០ ត្រូវបានយកមកអនុវត្ត។

៣៨ ស្តង់ដារនេះ តំរូវឱ្យមានការអនុវត្តផ្សេងគ្នា ពីស.គ.អ.ក ២០ ប្រសិនបើអំណោយរដ្ឋាភិបាលពាក់ពន្ធ័ទៅនឹង ទ្រព្យសកម្មជីវសាស្ត្រ ដែលវាស់វែងតាមតំលៃទីផ្សាររបស់វា ដកចេញ ថ្លៃដើមប៉ាន់ស្មានត្រង់ចំណុចលក់ ឬ អំណោយរដ្ឋាភិបាលតម្រូវឱ្យសហគ្រាសមួយមិនឱ្យចូលរួមក្នុងសកម្មភាពកសិកម្មជាក់លាក់ណាមួយ ។ ស.គ.អ.ក ២០ អនុវត្តតែចំពោះអំណោយរដ្ឋាភិបាលដែលទាក់ទងទៅនឹងទ្រព្យសកម្មជីវសាស្ត្រដែលវាស់វែងជាថ្លៃដើមរបស់វាដកចេញរំលស់បង្គរ និងការខាតបង់ដោយសារការថយចុះតំលៃបូកបន្តប៉ុណ្ណោះ។

## ការលាតត្រដាងព័ត៌មាន

៣៩ [លុបចោល]

### ភាពទូទៅ

**៤០ សហគ្រាសមួយ ត្រូវលាតត្រដាងព័ត៌មានអំពីចំណេញ ឬខាតសរុប ដែលកើតឡើងក្នុងគ្រាបច្ចុប្បន្ននៅពេលទទួលស្គាល់ដំបូងនៃទ្រព្យសកម្មជីវសាស្ត្រ និងផលិផលកសិកម្ម និងកើតចេញពីការផ្លាស់ប្តូរតម្លៃសមស្របរបស់វាដកចេញថ្លៃដើមប៉ាន់ស្មានដើម្បីលក់។**

**៤១ អង្គភាពត្រូវផ្តល់នូវការរៀបរាប់នៃក្រុមទ្រព្យជីវសាស្ត្រនីមួយៗ។**

៤២ ការលាតត្រដាងព័ត៌មាន តម្រូវដោយកថាខណ្ឌ ៤១ អាចនឹងមានទម្រង់ការពិពណ៌នាជាអត្ថបទ ឬ ជាបរិមាណ។

៤៣ សហគ្រាសមួយ ត្រូវបានលើកទឹកចិត្តឱ្យផ្តល់ការពិពណ៌នាជាបរិមាណនៃក្រុមនីមួយៗ នៃទ្រព្យសកម្មជីវសាស្ត្រ ដោយញែកឱ្យដាច់ពីគ្នារវាងទ្រព្យសកម្មជីវសាស្ត្រដែលផ្តល់ផលបន្ត និងប្រើប្រាស់អស់ ឬរវាងទ្រព្យសកម្ម ជីវសាស្ត្រដែលទុំជោរ និងមិនទុំជោរតាមភាពសមរម្យ ។ ឧទាហរណ៍ សហគ្រាសមួយ អាចលាតត្រដាងព័ត៌មាន អំពីតម្លៃយោងនៃទ្រព្យសកម្ម ជីវសាស្ត្រ ដែលផ្តល់ផលបន្ត និងប្រើប្រាស់អស់ទៅតាមក្រុម។ សហគ្រាសមួយ អាចនឹងបែងចែកតទៅទៀតនៃតម្លៃយោងរវាងទ្រព្យសកម្មទុំជោរ និងមិនទាន់ទុំជោរ ។ ភាពញែកពីគ្នានេះ ផ្តល់ព័ត៌មានដែលមានប្រយោជន៍ក្នុងការវាយតម្លៃ អំពីពេលវេលានៃលំហូរសាច់ប្រាក់ពេលអនាគត ។ អង្គភាពមួយ ត្រូវលាតត្រដាងពីមូលដ្ឋានសម្រាប់វិធីសាស្ត្រញែកចេញពីគ្នារបៀបនោះ។

៤៤ ទ្រព្យសកម្មជីវសាស្ត្រ ដែលប្រើប្រាស់អស់ ជាទ្រព្យទាំងឡាយណាដែលត្រូវប្រមូលផលជាផលិតផលកសិកម្ម ឬលក់ជាទ្រព្យសកម្មជីវសាស្ត្រ។ ឧទាហរណ៍នៃទ្រព្យសកម្មជីវសាស្ត្រដែលប្រើប្រាស់អស់ គឺសត្វចិញ្ចឹមសម្រាប់ផលិតសាច់ សត្វចិញ្ចឹមសម្រាប់លក់ ត្រីនៅក្នុងកសិដ្ឋាន ដំណាំដូចជា ពោត និងស្រូវសាលី ដើមឈើដាំសម្រាប់ធ្វើឈើអារ។ ទ្រព្យសកម្មជីវសាស្ត្រ ដែលផ្តល់ផលបន្ត ជាទ្រព្យទាំងឡាយណាក្រៅពីទ្រព្យសកម្មជីវសាស្ត្រដែលប្រើប្រាស់អស់ ឧទាហរណ៍ ដូចជា សត្វចិញ្ចឹមសម្រាប់ផលិតទឹកដោះ ដើមទំពាំងបាយជូរ ដើមឈើហូបផ្លែ និងដើមឈើដែលផ្តល់ផលជាឈើ ហើយដើមឈើនោះនៅដដែល។ ទ្រព្យសកម្មជីវសាស្ត្រ

ដែលផ្តល់ផលបន្ត មិនមែនជាផលិតផលកសិកម្មទេ ប៉ុន្តែជាការបង្កើតឡើងវិញ ដោយខ្លួនឯង។

៤៥ ទ្រព្យសកម្មជីវសាស្ត្រ អាចត្រូវគេចំណាត់ថ្នាក់ ជាទ្រព្យសកម្មជីវសាស្ត្រទុំជោរ ឬមិនទាន់ទុំជោរ ។ ទ្រព្យសកម្មជីវសាស្ត្រទុំជោរ ជាទ្រព្យសកម្មជីវសាស្ត្រទាំងឡាយណាដែលឈានដល់កំរិតអាចប្រមូលផលបាន( សម្រាប់ទ្រព្យសកម្មជីវសាស្ត្រដែលប្រើប្រាស់អស់ ) ឬដែលអាចផ្តល់ផលជាទៀងទាត់ ( សម្រាប់ទ្រព្យសកម្មជីវសាស្ត្រដែលផលិតផលបន្ត)។

៤៦ **ប្រសិនបើ មិនបានលាតត្រដាងនៅកន្លែងណាផ្សេងទេ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ សហគ្រាសមួយគួរតែពិពណ៌នាអំពី ÷**

(ក) **លក្ខណៈនៃសកម្មភាពរបស់ខ្លួន ដែលពាក់ពន្ធ័ទៅនឹងក្រុមនីមួយៗនៃទ្រព្យសកម្មជីវសាស្ត្រ និង**

(ខ) **ការវាស់វែងមិនមែនហិរញ្ញវត្ថុ ឬ ការប៉ាន់ស្មាននៃបរិមាណរូបវ័ន្តនៃៈ**

(១) **ក្រុមនីមួយៗនៃទ្រព្យសកម្មជីវសាស្ត្ររបស់សហគ្រាសនៅចុងការិយបរិច្ឆេទ និង**

(២) **ផលិតផលនៃផលិតផលកសិកម្ម ក្នុងកំឡុងការិយបរិច្ឆេទ**

៤៧ **សហគ្រាសមួយ ត្រូវលាតត្រដាងអំពីវិធីសាស្ត្រ និងការសន្មតសំខាន់ៗដែលប្រើប្រាស់ នៅក្នុងការកំណត់តម្លៃសមស្រប នៃក្រុមផលិតផលកសិកម្មនីមួយៗ នៅចំនុចប្រមូលផល និងក្រុមនីមួយៗនៃទ្រព្យសកម្មជីវសាស្ត្រ។**

៤៨ **សហគ្រាសមួយ ត្រូវបង្ហាញអំពីតំលៃសមស្របដកចេញថ្លៃដើមដើម្បីលក់នៃផលិតផលកសិកម្ម ដែលបានប្រមូលផល ក្នុងកំឡុងការិយបរិច្ឆេទដែលបានកំណត់នៅចំនុចប្រមូលផល ។**

៤៩ សហគ្រាសមួយត្រូវលាតត្រដាងអំពី÷

(ក) អត្ថិភាព និងតម្លៃយោងនៃទ្រព្យសកម្មជីវសាស្ត្រ ដែលកម្មសិទ្ធិរបស់វា ត្រូវគេដាក់កំហិត និងតម្លៃយោងនៃទ្រព្យសកម្មជីវសាស្ត្រ ដែលបានដាក់តំកល់ជាវត្ថុបញ្ចាំចំពោះបំណុលណាមួយ ។

(ខ) បរិមាណនៃការសន្យាសម្រាប់ការអភិវឌ្ឍ ឬការទិញនៃទ្រព្យសកម្មជីវសាស្ត្រ

(គ) យុទ្ធសាស្ត្រនៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ ដែលពាក់ពន្ធ័ទៅនឹងសកម្មភាពកសិកម្ម ។

៥០ សហគ្រាសមួយ គួរតែលាតត្រដាងនូវការផ្ទៀងផ្ទាត់ នៃការផ្លាស់ប្តូរតម្លៃយោង នៃទ្រព្យសកម្មជីវសាស្ត្រ រវាងពេលចាប់ផ្តើម និង ចុងការិយ-បរិច្ឆេទបច្ចុប្បន្ន ។ ការផ្ទៀងផ្ទាត់នោះ រួមមាន ÷

(ក) ចំណេញ ឬខាតពីការប្រែប្រួលនៃតម្លៃសមស្រប ដកចេញថ្លៃដើមដើម្បីលក់

(ខ) ការកើនឡើងដោយសារការទិញចូលបន្ថែម

(គ) ការថយចុះ ដោយសារការលក់ចេញ និងទ្រព្យសកម្មជីវសាស្ត្រ ត្រូវបានចំណាត់ថ្នាក់ ជាទ្រព្យ សម្រាប់លក់ (ឬក៏ បញ្ចូលទៅក្រុមទ្រព្យសម្រាប់លក់) ដោយយោងតាម ស.រ.ហ.អ.ក ៥

(ឃ) ការថយចុះដោយសារការប្រមូលផល

(ង) ការកើនឡើង ដោយសារការបញ្ចូលអាជីវកម្មរួមគ្នា

(ច) ភាពខុសគ្នានៃអត្រាប្តូរប្រាក់ពិត ដែលកើតចេញពីការប្រែសម្រួលរបាយការណ៍ហិរញ្ញវត្ថុ ទៅជារូបិយប័ណ្ណបង្ហាញមួយផ្សេងទៀត

និងការបកប្រែនៃប្រតិបត្តិការបរទេស ទៅជារូបិយប័ណ្ណបង្ហាញនៃសហគ្រាសរាយការណ៍ និង

(ឆ) ការប្រែប្រួលផ្សេងទៀត ។

៥១ តម្លៃសមស្រប ដកចេញ ថ្លៃដើមដើម្បីលក់នៃទ្រព្យសកម្មជីវសាស្ត្រមួយអាចប្រែប្រួលដោយសារតែការប្រែប្រួលរូបធាតុ និងការប្រែប្រួលថ្លៃនៅក្នុងទីផ្សារ។ ការបង្ហាញព័ត៌មានដាច់ដោយឡែក នៃការប្រែប្រួលរូបធាតុ និងការប្រែប្រួលតម្លៃ មានសារៈប្រយោជន៍ ក្នុងការវាយតំលៃលទ្ធផល នៃការិយបរិច្ឆេទបច្ចុប្បន្ន និងលទ្ធផលអនាគត ជាពិសេស ពេលដែលមានវដ្តផលិតកម្មច្រើនជាងមួយឆ្នាំ ។ ក្នុងករណីនេះ សហគ្រាសមួយត្រូវបានលើកទឹកចិត្តឱ្យបង្ហាញជាក្រុម ឬអ្វីផ្សេងទៀតនូវបរិមាណ នៃការប្រែប្រួលតម្លៃសមស្រប ដកចេញថ្លៃដើមប៉ាន់ស្មានត្រង់ចំណុចលក់ ដែល បានបញ្ចូលទៅក្នុងចំណេញខាតដោយសារការប្រែប្រួលរូបធាតុ និងដោយសារការប្រែប្រួលថ្លៃ ។ ព័ត៌មាននេះ ជាទូទៅមានប្រយោជន៍កាន់តែតិចពេលដែលវដ្តផលិតកម្មមានរយៈពេលតិចជាងមួយឆ្នាំ (ឧទាហរណ៍ ពេលដែលចិញ្ចឹមមាន់ ឬដាំដំណាំធញ្ញជាតិ)។

៥២ ការបម្លែងតាមជីវសាស្ត្រ ផ្តល់លទ្ធផលជាប្រភេទផ្សេងៗគ្នា ការប្រែប្រួលរូបធាតុ កំណើនការពុកផុយ ផលិតកម្ម និងជាតិកម្មដែលមួយៗ អាចធ្វើការសង្កេត និងវាស់វែងបាន។ ការប្រែប្រួលរូបធាតុទាំងនេះ មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត ។ ការប្រែប្រួលនៃតំលៃទីផ្សាររបស់ទ្រព្យ សកម្មជីវសាស្ត្រ ដោយសារការប្រមូលផលក៏ជាការប្រែប្រួលរូបធាតុផងដែរ។

៥៣ សកម្មភាពកសិកម្ម ជារឿយៗ ប្រឈមទៅនឹងបញ្ហាធាតុអាកាស ជំងឺ និងហានិភ័យធម្មជាតិដទៃទៀត ។ ប្រសិនបើព្រឹត្តិការណ៍មួយកើតឡើង ហើយបង្កើតឱ្យមានជាទំហំធំ នៃចំណូល និងចំណាយនោះ ប្រភេទ និងចំនួនទឹកប្រាក់របស់វា ត្រូវបង្ហាញដោយយោងទៅតាម ស.គ.អ.ក ១ *ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ* ។ ឧទាហរណ៍នៃព្រឹត្តិការណ៍នោះ រួមបញ្ចូលការផ្ទុះឡើងនៃជំងឺឆ្លង ទឹកជំនន់ គ្រោះរាំងស្ងួតធ្ងន់ធ្ងរ ឬកំណក និងសត្វល្អិត។

**ការលាតត្រដាងព័ត៌មានបន្ថែម សម្រាប់ទ្រព្យសកម្មជីវសាស្ត្រ ពេលដែលតំលៃសមស្រប របស់វា មិនអាចវាស់វែងបានដោយជឿជាក់**

៥៤ ប្រសិនបើសហគ្រាសមួយ វាស់វែងទ្រព្យសកម្មជីវសាស្ត្រ ដោយប្រើថ្លៃដើមរបស់វា ដកចេញរំលស់បង្គរ និង ការខាតបង់បូកបង្គរដោយការខូចខាតតម្លៃ (សូមមើលកថាខណ្ឌ ៣០) នៅចុងការិយបរិច្ឆេទ សហគ្រាសនោះត្រូវតែលាតត្រដាងព័ត៌មាន សម្រាប់ទ្រព្យសកម្មជីវសាស្ត្រនោះ ដូចខាងក្រោម ÷

(ក) ការពិពណ៌នាអំពីទ្រព្យសកម្មជីវសាស្ត្រ

(ខ) ការពន្យល់មូលហេតុ ហេតុអ្វីបានជាតម្លៃសមស្រប មិនអាចវាស់វែងបានដោយជឿជាក់

(គ) ប្រិសនបើអាច សូមបង្ហាញពីចន្លោះនៃការប៉ាន់ស្មាន ដែលតម្លៃសមស្របទំនងជាស្ថិតនៅពីប៉ុន្មាន ទៅប៉ុន្មាន។

(ឃ) វិធីសាស្ត្ររំលស់ដែលប្រើ

(ង) អាយុកាលប្រើប្រាស់ ឬ អត្រារំលស់ដែលបានប្រើប្រាស់ និង

(ច) ចំនួនទឹកប្រាក់ដុលនៃតម្លៃយោង និងរំលស់សរុបបន្ត (បូកបន្ថែមជាមួយការខាតបង់ដោយការធ្លាក់ចុះតំលៃបូកបន្ត ) នៅដើមការិយបរិច្ឆេទ និងចុងការិយបរិច្ឆេទ។

៥៥ ប្រសិនបើក្នុងកំឡុងពេលបច្ចុប្បន្ន សហគ្រាសមួយ វាស់វែងទ្រព្យសកម្មជីវសាស្ត្រ ដោយប្រើថ្លៃដើមរបស់វា ដកចេញរំលស់បូកបន្ត និងការខាតបង់ដោយការខូចខាតតំលៃបូកបន្ត (សូមមើលកថាខណ្ឌ ៣០) សហគ្រាសនោះ ត្រូវបង្ហាញព័ត៌មានអំពីចំណេញ ឬខាតណាមួយ ដែលទទួលស្គាល់នៅពេលលក់បញ្ចេញចោលនៃទ្រព្យសកម្មជីវសាស្ត្រនោះ ហើយការផ្ទៀងផ្ទាត់មួយ ដែលត្រូវធ្វើឡើងយោងតាមកថាខណ្ឌ ៥០ ត្រូវលាតត្រដាងអំពីបរិមាណទឹកប្រាក់ទាក់ទងទៅនឹង ទ្រព្យសកម្មជីវសាស្ត្រនោះដាច់ដោយឡែកពីគ្នា ។ បន្ថែមលើនេះទៀត ការកែសម្រួលនេះ ត្រូវបូកបញ្ចូលនូវទឹកប្រាក់ដូចខាងក្រោម ទៅក្នុងចំណេញឬខាត ពិតពាក់ពន្ធ័ ទៅនឹងទ្រព្យសកម្មជីវសាស្ត្រទាំងនោះ ÷

(ក) ការខាតបង់ដោយសារការធ្លាក់ចុះតំលៃ

(ខ) ការត្រឡប់វិញ នៃការខាតបង់ដោយសារការធ្លាក់ចុះតំលៃ និង

(គ) រំលស់

៥៦ ប្រសិនបើតំលៃសមស្របនៃទ្រព្យសកម្មជីវសាស្ត្រ ត្រូវបានគេវាស់វែងពីគ្រាមុនៗ ដោយប្រើថ្លៃដើមរបស់វា ដកចេញរំលស់បូកបន្ត និងការខាតពីការធ្លាក់ចុះតម្លៃបូកបន្តបានក្លាយទៅជា អាចវាស់វែង បានដោយ ជឿជាក់ក្នុងកំឡុងការិយបរិច្ឆេទបច្ចុប្បន្ន សហគ្រាសមួយត្រូវបង្ហាញចំពោះទ្រព្យសកម្មជីវសាស្ត្រទាំងនោះអំពីៈ

(ក) ការពិពណ៌នាអំពីទ្រព្យសកម្មជីវសាស្ត្រ

(ខ) ការពន្យល់ពីមូលហេតុ ដែលតម្លៃសមស្រប ក្លាយជាការអាចវាស់វែងបានដោយជឿជាក់

(គ) ផលប៉ះពាល់នៃការផ្លាស់ប្តូរ ។

ជំនួយរដ្ឋាភិបាល

៥៧ សហគ្រាសមួយ ត្រូវលាតត្រដាងបង្ហាញព័ត៌មានខាងក្រោម ពាក់ពន្ធ័ទៅនឹងសកម្មភាពកសិកម្មដែលគ្របដណ្តប់ដោយស្តង់ដារនេះ ÷

(ក) លក្ខណៈ និងទំហំនៃជំនួយរដ្ឋាភិបាល ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(ខ) លក្ខខណ្ឌមិនទាន់បានបំពេញ និងយថាហេតុផ្សេងទៀត ដែលភ្ជាប់ទៅនឹងជំនួយរដ្ឋាភិបាល

(គ) ការថយចុះសំខាន់ៗ ដែលរំពឹងថានឹងកើតឡើងចំពោះកម្រិតនៃជំនួយរដ្ឋាភិបាល

## ថ្ងៃចូលជាធរមាន និងអន្តរកាល

៥៨ ស្តង់ដានេះ អាចអនុវត្តបាន សម្រាប់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលគ្របដណ្តប់ការិយបរិច្ឆេទ ចាប់ផ្តើមនៅថ្ងៃទី ឬបន្ទាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០០៣ ។ ការអនុវត្តមុនការិយបរិច្ឆេទនេះ ត្រូវបានលើកទឹកចិត្ត។ ប្រសិនបើសហគ្រាសមួយប្រើប្រាស់ស្តង់ដានេះ សម្រាប់ចាប់ផ្តើមការិយ-បរិច្ឆេទមុនថ្ងៃ០១ ខែមករា ឆ្នាំ២០០៣សហគ្រាសនោះត្រូវលាតត្រដាងសាច់រឿងនេះ ។

៥៩ ស្តង់ដានេះ មិនបានបង្កើត នូវអន្តរបញ្ញត្តិក្នុងពេលអន្តរកាលបណ្តោះអាសន្នណាមួយ ដោយជាក់លាក់ឡើយ ។ ការប្រើស្តង់ដានេះ ត្រូវបានធ្វើគណនេយ្យកម្មដោយយោងទៅតាម ស.គ.អ.ក៨ *គោលនយោបាយគណនេយ្យ ការផ្លាស់ប្តូរនៃការប៉ាន់ស្មានគណនេយ្យ និងកំហុសឆ្គង* ។

៦០ កថាខណ្ឌ ៥ ៦ ១៧ ២០ និង ២១ ត្រូវបានធ្វើវិសោធនកម្ម និង កថាខណ្ឌ ១៤ ត្រូវបានលុបចោល ដោយ *ការធ្វើឱ្យប្រសើរឡើងចំពោះ ស.រ.ហ.អ.ក* ដែលបានចេញផ្សាយនៅក្នុងខែឧសភា ឆ្នាំ២០០៨។ អង្គភាពមួយត្រូវប្រើវិសោធនកម្ម ទាំងនោះទៅពេលខាងមុខសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំដែលចាប់ផ្តើមនៅថ្ងៃទី ឬបន្ទាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩។ ការអនុវត្តមុនកាលកំណត់ត្រូវបានអនុញ្ញាត ។ ប្រសិនបើសហគ្រាសមួយប្រើវិសោធនកម្មសម្រាប់ការិយបរិច្ឆេទមុន សហគ្រាសត្រូវលាតត្រដាងពីហេតុការណ៍នោះ ។

ក្រុមប្រឹក្សាជាតិគណនេយ្យ

ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា

អាស័យដ្ឋានៈ ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា

អ៊ីម៉ែលៈ info@naccambodia.gov.kh | គេហទំព័រៈ www.naccambodia.gov.kh



ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ